# III. ការងារបណ្ដាក្រសួង

## ១ - លិខិតការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច - ហិរញ្ញវត្ថុ

ភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

## សេចក្ដីជូនដំណឹងលេខ ០៣២ កបាវ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ

**សូមទូលថ្វាយនិងជំរាបមក**

- ព្រះអង្គម្ចាស់ ឯកឧត្ដមរដ្ឋមន្ត្រីគ្រប់ក្រសួង
- ឯកឧត្ដមរដ្ឋលេខាធិការគ្រប់ស្ថាប័ន
- ឯកឧត្ដមអភិបាលខេត្ត ក្រុង

**កម្មវត្ថុ :** អំពីប្រាក់បៀវត្សរ៍បន្ថែម ២០ ភាគរយរបស់មន្ត្រីរាជការ

**យោង :** សេចក្ដីជូនដំណឹងលេខ ០១៣ សជណ. កហវ. ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៣ ។

តាមខ្លឹមសារនៃសេចក្ដីជូនដំណឹងនិងស្ថានភាពថ្លៃទំនិញដូចមានក្នុងយោងខាងលើ ទូលបង្គំខ្ញុំ សូមទូលថ្វាយ និងជំរាបព្រះអង្គម្ចាស់ និងឯកឧត្ដមថា : ចាប់ពីខែ តុលា ឆ្នាំ ១៩៩៣ នេះតទៅ ប្រាក់បៀវត្សរបស់មន្ត្រីរាជការ ម្នាក់ៗ ក្នុង ១ ខែ ត្រូវបន្ថែមថ្លៃ "២០ ភាគរយ" លើបៀវត្ស សុទ្ធសាធរបស់សាមីខ្លួន ។

អាស្រ័យហេតុនេះសូមព្រះអង្គម្ចាស់ ឯកឧត្ដមរដ្ឋមន្ត្រី ឯកឧត្ដមរដ្ឋលេខាធិការ និងអភិបាលខេត្ត ក្រុង មេត្តាធ្វើការណែនាំអោយអនុវត្តតាមខ្លឹមសារខាងលើតាមការគួរ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
**សម រង្ស៊ី**

********